**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០៥ សរ**

# សារាចរ

## ស្តីពី

## ការដឹកជញ្ជូនឈើ សំភារៈ និងទំនិញ លើផ្លូវថ្នល់ ក្នុងព្រះរាជាណាចក្រកម្ពុជា

ដោយកន្លងមកគ្រោះធម្មជាតិទឹកជំនន់ក្នុងឆ្នាំ ២០០០ បានបំផ្លាញអាយុជីវិត ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធ មានសាលារៀន មន្ទីរពេទ្យ សំណង់ធារាសាស្ត្រ ផ្លូវលំ ស្ពាន និងផ្លូវជាតិអស់ជាច្រើន ។ រាជរដ្ឋាភិបាលបានខិតខំកៀងគរជំនួយ ហើយបានប្រើប្រាស់ហិរញ្ញប្បទានជាជំនួយឥតសំណង និងកម្ចីពីសហគមន៍អន្តរជាតិ ព្រមទាំងបានប្រើប្រាស់ថវិកាជាតិផ្ទាល់អស់ជាច្រើន ដើម្បីស្តារ និងជួសជុលជាបន្ទាន់នូវការខូចខាត ដើម្បីធ្វើអោយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាព សេដ្ឋកិច្ច- សង្គមកិច្ច មានដំណើរការជាប្រក្រតីឡើងវិញ ។ នៅក្នុងឆ្នាំ ២០០១ នេះ ទឹកជំនន់ក៏បានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ តាមបណ្តាខេត្ត ក្រុងជាប់ទន្លេមេគង្គ ហើយក៏បង្កអោយមានការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធដែលទើបស្តារ និងជួសជុលឡើងវិញនោះ ត្រូវរងការខូចខាតជាថ្មីម្តងទៀត ជាពិសេសផ្លូវជាតិ ស្ពាន និងផ្លូវលំជាដើម ។ ប៉ុន្តែក្នុងការខូចខាតផ្លូវជាតិ ស្ពាន និងផ្លូវលំនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ក្រៅពីគ្រោះមហន្តរាយបង្កឡើងដោយគ្រោះធម្មជាតិ គឺមានករណីជាច្រើនដែលបណ្តាលមកពីរថយន្តដឹកឈើរបស់ក្រុមហ៊ុនព្រៃសម្បទាន និងរថយន្តដឹកអុសដើមកៅស៊ូ សំភារៈ គ្រឿងចក្រ ទំនិញផ្សេងៗគ្រប់ប្រភេទ ច្រើនហួសហេតុលើសបន្ទុកដែលបានកំណត់ ។ ដើម្បីការពារ ថែរក្សាផ្លូវជាតិ ស្ពាន និងផ្លូវលំ រាជរដ្ឋាភិបាលសូមដាក់ចេញនូវបទបញ្ជាដូចតទៅ ÷

១- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសណែនាំជាបន្ទាន់ដល់ម្ចាស់ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ ដើម្បីកំណត់អំពីបរិមាណ និងទំងន់ឈើគិតអតិបរមា ដែលត្រូវដឹកជញ្ជូនលើផ្លូវជាតិ ស្ពាន និងផ្លូវលំ សំដៅដាក់អោយម្ចាស់ក្រុមហ៊ុនព្រៃសម្បទានអនុវត្ត ដោយធានាអោយបាននិរន្តភាពនៃហេដ្ឋារចនាសម្ព័ន្ធខាងលើ ។ ក្នុងករណីមានបទល្មើសជាក់ស្តែងនឹងប្រកាសនេះ មន្ត្រីរុក្ខាប្រមាញ់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវឃាត់ទុកមធ្យោបាយ និងជនល្មើស ដើម្បីមានវិធានការតាមផ្លូវច្បាប់ ដោយបិទរោងចក្រ និងដកហូតព្រៃសម្បទានមកវិញ ព្រមទាំងចាប់បង្ខំអោយធ្វើការជួសជុលសងការខូចខាតនោះថែមទៀត ។

២- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវចេញប្រកាសណែនាំជាបន្ទាន់ ដើម្បីកំណត់អំពីបរិមាណ និងទំងន់អុសដើមកៅស៊ូ សំភារៈ គ្រឿងចក្រ និងទំនិញគ្រប់ប្រភេទ គិតអតិបរមា ដែលត្រូវដឹក

ជញ្ជូនលើស្ពាន និងផ្លូវថ្នល់ សំដៅដាក់អោយម្ចាស់ក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូន និងអ្នកដឹកអុស ដើមកៅស៊ូ សំភារៈ គ្រឿងចក្រ ទំនិញគ្រប់ប្រភេទ អនុវត្តអោយបានត្រឹមត្រូវជាដាច់ខាត តាមការកំណត់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ។ ក្នុងករណីមានបទល្មើសជាក់ស្តែងនឹងប្រកាសនេះ មន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវឃាត់ទុកមធ្យោបាយ និងជនល្មើស ដើម្បីមានវិធានការតាមផ្លូវច្បាប់ ដោយបញ្ឈប់ជាស្ថាពរនូវសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ឬរបស់ជនល្មើស ដោយត្រូវដកហូតលិខិតអនុញ្ញាតមិនអោយធ្វើអាជីវកម្មដឹកជញ្ជូនតទៅទៀត និងដកហូតជាស្ថាពរនូវប័ណ្ណបើកបរ ព្រមទាំងបង្ខំអោយធ្វើការជួសជុលសងការខូចខាតស្ពាន និងផ្លូវថ្នល់ថែមទៀត ។

៣- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គនាយកនគរបាលជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវដឹកនាំកិច្ចសហការ និងធ្វើជាកម្លាំងស្នូលក្នុងការធ្វើអន្តរាគមន៍ជាបន្ទាន់ដល់មន្ត្រីរុក្ខាប្រមាញ់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើល្មើសនៃការដឹកជញ្ជូនឈើ អុសដើមកៅស៊ូ សំភារៈ គ្រឿងចក្រ និងទំនិញគ្រប់ប្រភេទលើសទំងន់កំណត់លើផ្លូវថ្នល់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- មន្ត្រីនៃក្រសួងស្ថាប័នមានសមត្ថកិច្ចទាំងឡាយណា ដែលធ្វេសប្រហែសមិនបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យ និងទប់ស្កាត់អោយមានប្រសិទ្ធភាព នូវការដឹកជញ្ជូនឈើ អុសដើមកៅស៊ូ សំភារៈ គ្រឿងចក្រ និងទំនិញគ្រប់ប្រភេទលើសទំងន់កំណត់ ដែលចរាចរនៅលើផ្លូវថ្នល់នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងរាជរដ្ឋាភិបាល ។

គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីគ្រប់ខេត្ត ក្រុង ត្រូវសហការបន្ទាន់ជាមួយមន្ត្រីរុក្ខាប្រមាញ់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីអនុវត្តតាមខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាព នៅពេលទទួលបានសារាចរនេះ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល*
- *គ្រប់សាលាខេត្ត-ក្រុង*
- *ឯកសារ-កាលប្បវត្តិ*